# ពាក្យបណ្តៅបុរាណ

(ពាក្យ ៨)

១. ចំណីនាសា ប្រៀបដូចអាហារ បញ្ញាគាប់ចិត្ត
បានហើយកៀកអោប អបអរពេកពិត បានត្រឹមតែហិត
ក្រោយមកបោះបង់ ។

ចម្លើយ: ផ្កា---បុប្ផនានា

២. ដុំលោហធាតុ នាំគ្នាឱហាត សង្វាតប្រឹងរក
លោកឲ្យតម្លៃ គ្មានពេលថយថោក ជននៅក្នុងលោក
យកជាដើមទុន ។

ចម្លើយ: មាស, ប្រាក់សាច់

៣. សិលាធម្មជាតិ សថ្លាសារធាតុ មានឧរឹងលើសគេ
មនុស្សលោកចង់បាន អាចថ្លៃខ្ពស់ទ្វេ បានទុកជាកេរ្តិ៍
ផ្ទេរអលង្ការ ។

ចម្លើយ: ត្បូងពេជ្រ

៤. បណ្ណពណ៌រចនា មានហត្ថលេខា នឹងត្រាតម្លៃ
ជនគ្រប់ប្រទេស លោកខាងសេរី ប្រើប្រាស់រាល់ថ្ងៃ
ថ្លៃដូររបស់ ។

ចម្លើយ: ក្រដាស់ប្រាក់

៥. ធម្មជាតិថ្មកប់ មានពណ៌គ្រប់សព្វ ជាប់ល្អពន្លឺ
ធ្វើអលង្ការ កញ្ញាចោមមើល ថ្លៃថ្លាប្រសើរ
ដើមថ្លៃខុសគ្នា ។
ចម្លើយ: ត្បូងគ្រប់ព៌ណ

៦. ជនមិនមែនសត្វ ងារជាប់មិនបាត់ ព្រោះហ៊ានការពារ
ទឹកដីពលរដ្ឋ រាំងព័ទ្ធសីមា ថាជានាមទា
គ្នានោះជាអ្វី ?
ចម្លើយ: ទាហាន ឬយុទ្ធជន

៧. ផល្លារុក្ខជាតិ ស៊ីឆ្ងាញ់ខុសគ្នា វានេះខុសគេ
ជនចេញទឹកភ្នែក ក្រោយទំពារលេប រួចវាឲ្យហេតុ
ហូរហៀរសំបោរ ។
ចម្លើយ: ផ្លែម្ទេសគ្រប់ប្រភេទ

៨. រុក្ខជាតិមួយពួក មានដើមត្រង់ខ្ពស់ គ្មានមែកសាខា
ដើមញីផ្ដល់ផ្លែ មកយើងពិសារ ឯឈ្មោលឲ្យផ្កា
ផ្ដល់ទឹកដល់យើង ។
ចម្លើយ: ដើមត្នោតញី ឈ្មោល

៩. នៅក្នុងពិភព អ្នកមួយដើរយប់ គេឯងឃើញប្រាណ
ត្បិតគោមបំភ្លឺ ពន្លឺដូរបាន តូចធំតាមកាល
ឆ្ងាយខ្ពស់ផុតយើង ។
ចម្លើយ: ព្រះច័ន្ទ

១០. គ្រូពាក្យអក្សរ មិនដើរចេញចរ ចុះឡើងទៅណា
សិស្សអ្នកចង់សួរ ទាញគ្រូមកថា មើលយល់សាច់ការ
ភាសាគ្រូប្រាប់ ។
ចម្លើយ: សៀវភៅវចនានុក្រម

១១. ចំណីមួយពួក ជនស៊ីរីវក់ ជញ្ជក់យកជាតិ
អស់រសកាលណា ហារមាត់ជុះខ្លាក ក្នុងបង្កន់កៀក
ទាញក្រោកក្បែរអង្គ ។
ចម្លើយ: ស៊ីម្លូស្លា, ខ្ជាក់ដាក់កន្ថោរ

១២. វិមានចុងមែក គេហាចម្លែក មនុស្សជាតិសរសើរ
ព្រោះសាងមិនដូច សត្វតូចបានធ្វើ ដាក់កូនទុំទើរ
ទាយមើលថាអ្វី ។
ចម្លើយ: សំបុកចាបព្បរ

១៣. មាននំមួយនោះ ឆ្ងុយឆ្ងាញ់ឥតខ្ចោះ ហើយមានតម្លៃ
ព្រោះគេបានរោយ ល្វពណ៌ប្រពៃ តែមិនអាចឆី
បានត្រឹមតែមើល ។
ចម្លើយ: សៀវភៅ

១៤. ពាក្យផ្ទុះពីខឹង ប៉ះភាគីម្ខាង ច្រងាងឈឺចាប់
កើតជាជម្លោះ ទាស់គ្នាអឹងអាប់ សូមអ្នកបកប្រាប់
ស័ព្ទនោះជាអ្វី ។
ចម្លើយ: ពាក្យជេរគ្នា

(ពាក្យ ៧)

១៥. ឃើញបាត់ៗ រសាត់ផុត តែមិនរបូតវិលមកវិញ
ដូចបងប្អូនពីរនាក់រត់ដេញ ពេលខុសគ្នាពេញក្ដៅត្រជាក់។
ចម្លើយ: ព្រះអាទិត្យ ព្រះច័ន្ទ

១៦. មាននំមួយតែងភូតអ្នកដើរ ថាវាបំរើដល់មាត់គេ
ពេលស្រូបវានៅស្មៀមទទេ អ្នកទិញរិះរេប្រើងខ្លួនឯង ។
ចម្លើយ: នំបញ្ចុក

១៧. នាវាមួយហាក់ធំអស្ចារ្យ ព្រោះដាក់មនុស្សម្នាបានច្រើនក្រៃ
ប៉ុន្តែមិនអាចដាក់គ្រាប់ខ្សាច់ដី តើធំប៉ុនអ្វីសូមអ្នកឆ្លើយ ។
ចម្លើយ: ធំប៉ុនគ្រាប់ភ្នែក គឺភ្នែកទាំងសងខាង

១៨. រូបអ្នកទាំងពីរកាលពេញវ័យ ស្ម័គ្រចិត្តចាប់ដៃរួមជីវី
បង្កើតបញ្ហារស់មូលមី សព្វគ្រប់ទិសទីនោះគឺអ្វី ។
ចម្លើយ: ស្វាមីភរិយា, មាតាបិតា

១៩. វាជាអ្នកឆ្មាំចាំយាមទ្វារ មិនឲ្យនរណាចូលបៀនបៀត
រូបអ្នកម្ចាស់ទើបអនុញ្ញាត ព្រោះគេចោះក្បាលវានឹងដែក។
ចម្លើយ: មេសោទ្វារ និងកូនសោ

២០. មានសត្វពីរពួកដេកខុសគ្នា ១ ចូលចិត្តរងា ២ ចូលចិត្តស្ងួត
វាកើតពីរតតំណរពូជ របូតផុតរួចពីក្នុងថ្ម ។
ចម្លើយ: ពពួកសត្វមាន់ និងសត្វទា

២១. យើងដើរបាលក្តៅតែម្នាក់ឯង តែមានគេដើងមិនចេះចប់
វាខំដើរតាមឲ្យចំប្រប់ លុះយើងចូលម្លប់វាគេចចេញ។
ចម្លើយៈ ស្រមោលខ្លួនឯង
២២. បាទាទាំងទ្វេមេចែកដោយ អាវុធទុកឲ្យជាប់របូត
ទោះដេកឬដើរមិនរបូត វាខំតែលូតស្រួចមុតថែម ។
ចម្លើយៈ ខ្នាយមាន់ឈ្មោល
២៣. អាវុធសម្ងាត់បាត់ក្នុងសាច់ គេឯងខ្លបខ្លចពេលគាត់ខឹង
បញ្ចេញតតាំងបានយើងដឹង ខំប្រឹងដេកផ្ងាត្រាបានឈ្នះ ។
ចម្លើយៈ ក្រចកឆ្មា ឬក្រចកខ្លា
២៤. ស្វាមីភរិយាគ្នាទាំងទ្វេ ការងារមានដែរតែលើសគ្នា
ស្វាមីលើស ១ តើត្រង់ណា រីឯភរិយាលើស ១ វិញ ។
ចម្លើយៈ ស្វាមីលើស ១ ត្រង់បានបួស រីឯភរិយាលើស
១ ត្រង់បានសម្រាលកូនប្រុសស្រី
២៥. បាទា ៨ ឈានទៅខាង ហត្ថាច្រងាងមាឧខុសគ្នា
មានភ្នែកទាំងគូគន់ទិសា ខ្ពស់ផុតកាយាសម្លឹងគេ ។
ចម្លើយៈ ក្តាមគ្រប់ប្រភេទ
២៦. ដង្កូវយក្សមួយពាក់អាវដែក វាតែងលូនជ្រែកដងអរុធ្វា
លេបទាំងមនុស្សផងនានា
លឿនលូនវារពារកាត់ភូមិស្រុក។

ចម្លើយៈ រថភ្លើង, រទេះភ្លើង



២៧. មានអាគារមួយធំច្រងូវ ជាទីលំនៅក្មេងកុមារ
ពេលថ្ងៃពួកគេចូលត្រៀបត្រា ល្ងាចពេលណាពួកគេដើរចេញ។
ចម្លើយៈ សាលារៀន

២៨. ចំណីចុងមាត់ញាត់ដល់ធ្មេញ បឺតចូលបញ្ចេញភ្លើងនឹងផ្សែង
ប្រឹងស៊ីបន្តិចក៏អស់ឯង សល់គល់គ្រវែងចោលពុំស្ដាយ។
ចម្លើយៈ ជក់បារី

២៩. ធម្មជាតិមានរូបមើលពុំឃើញ នៅទំនើងពាសពេញផែនដី
ជនអាចរេចខ្ជប់លេងរាល់ថ្ងៃ ឲ្យជីវិតប្រុសស្រីទ្រទម្ងន់ ។
ចម្លើយៈ ខ្យល់ប៉ឺតប៉ោង

៣០. ពពួកសត្វល្អិតគិតសប្បាយ ហិចហើរប្រញាយក្បែរមាត់ព្រៃ
បង្ហួតប្រាណដល់អ្នកដទៃ មានរស្មីក្នុងរាត្រីកាល ។
ចម្លើយៈ ពពួកសត្វអំពឹលអំពែក

